២០១៥

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ០៧៦ MIH / 2015

## ប្រកាស
## ស្តីពីការបង្កើតក្រុមការងារផ្ទេរមុខងារ និងការធ្វើប្រតិភូកម្ម ជូនទៅថ្នាក់ក្រោមជាតិ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** ៖ បង្កើតក្រុមការងារផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មជូនទៅរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | គឹម ទូច | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម | អ៊ិច ប៉ូរ៉ា | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម | អ៊ុំ សុថា | អគ្គនាយកកិច្ចការទូទៅ | សមាជិក |
| ៤- | ឯកឧត្តម | សឹម ណារ៉ា | អគ្គនាយកឧស្សាហកម្ម | សមាជិក |
| ៥- | លោកជំទាវ | ពៅ វរលក្ស្មណ៍ | អគ្គនាយិកាសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | សមាជិក |
| ៦- | ឯកឧត្តម | ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ៧- | ឯកឧត្តម | ឡាំ គីមឡេង | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ៨- | លោក | ចាត សុសុភ័ក្រ | អគ្គនាយករងកិច្ចការទូទៅ | សមាជិក |
| ៩- | លោក | ប៊ី ពិទូរ្យ | អគ្គនាយករងឧស្សាហកម្ម | សមាជិក |
| ១០- | លោក | ហេង សោភ័ណ្ឌ | អគ្គនាយករងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | សមាជិក |
| ១១- | លោក | នូវ ថារ៉ា | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |

2015/1/09/Prakas transfer occupation/BPS/OST

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

| | | | | |
|---|---|---|---|---|
| ១២- | លោក | គឹម ចន្ទតារា | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |
| ១៣- | កញ្ញា | បុត្រ ភ័ក្ត្រសត្យា | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៤- | លោក | ញ៉ែម ចន្ទូ | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ១៥- | លោក | ចេង លឹមជី | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៦- | លោក | សេង ឆាង | ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម | សមាជិក |
| ១៧- | លោក | ឡុង បូរ៉ា | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១៨- | លោក | ទឹង សេរីវុធ | អនុប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៩- | លោក | ញ៉ែម ផល្លា | ប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក | លេខាធិការ |

**<u>ប្រការ២</u>** ៖ ក្រុមការងារនេះមានតួនាទី និងភារកិច្ច ដូចតទៅ ៖

- ធ្វើការពិនិត្យសិក្សាច្បាប់ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធមុខងាររបស់ជំនាញនីមួយៗ
- លើកមតិ និងរៀបចំឯកសារផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងកម្រិតដែលក្រសួងអនុញ្ញាត
- កំណត់កម្រិតនៃការផ្ទេរមុខងារដែលពុំមានផលប៉ះពាល់ដល់ច្បាប់នានារបស់ក្រសួង
- កំណត់មុខជំនាញនៃការធ្វើប្រតិភូកម្មតាមដំណាក់កាលនីមួយៗអោយបានសម្រេច
- អភិវឌ្ឍសមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិ ដើម្បីមានលក្ខណៈសម្បត្តិអាចទទួលការផ្ទេរមុខងារ ដែលក្រសួងបានផ្ទេរ ឬធ្វើប្រតិភូកម្ម
- សរុបលទ្ធផលនៃការអនុវត្តដំណើរការផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មជូន **ប្រធានស្ថាប័ន** ដើម្បីសុំមតិណែនាំ និងស្នើសុំការសម្រេច។

**<u>ប្រការ៣</u>** ៖ ប្រកាសលេខ៤១០ ឧរថ.បល.ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ស្តីពីការបង្កើតក្រុមការងារផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងប្រកាសលេខ៦១៨ ឧរថ.បល.ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការចាត់តាំងមន្ត្រីរាជការបន្ថែមក្នុងក្រុមការងារផ្ទេរមុខងារ និងការធ្វើប្រតិភូកម្មរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**<u>ប្រការ៤</u>** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីជន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

*« ដើម្បីជូនជ្រាប »*

-គ្រប់នាយកដ្ឋាន និងអង្គភាពថ្នាក់ស្មើ

-គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត

-ដូចប្រការ៤ *« ដើម្បីអនុវត្ត »*

-ឯកសារ-កាលប្បវត្តិ